

# ខ្ញុំមានមិត្តហើយ

The Asia Foundation - Let’s Read



វាតាសម្លឹងមើលមនុស្សជុំវិញខ្លួនដោយយកចិត្តទុកដាក់។ ស្រាប់តែ វាតា ឃើញក្មេងស្រីបីនាក់ សើចសប្បាយក្អាកក្អាយ។ ពួកគេ ពាក់ខ្សែកអង្កាំយ៉ាងស្រស់ស្អាតដូចៗគ្នា។ បេះដូងរបស់វាតាចាប់ផ្តើមលោតញាប់ខុសធម្មតា។

ចាប់តាំងពីគ្រួសាររបស់វាតាបានប្តូរផ្ទះថ្មីកាលពីបីសប្តាហ៍មុន នាងមិនដែលបានឃើញក្មេងៗដែលមាន អាយុស្រករនាងនៅម្តុំនោះឡើយ។



វាតាគិតតែម្នាក់ឯងថា៖ «តើខ្ញុំគួរនិយាយអ្វីទៅកាន់ក្មេងស្រីទាំងបីនាក់នោះ? តើពួកគេនឹងនិយាយជាមួយ ខ្ញុំដែរឬទេ? តើពួកគេនឹងចំអកឱ្យខ្ញុំដែរឬទេ?»

នៅពេលវាតា សម្លឹងមើលជុំវិញខ្លួនម្តងទៀត ស្រាប់តែក្មេងស្រីទាំងនោះបានចាកចេញពីទីនោះបាត់ទៅហើយ។

វាតា ដកដង្ហើមធំ «ហ៊ឹម។ ខ្ញុំប្រហែលជាមិនអាចមានមិត្តភក្តិថ្មីទេ មើលទៅ!»



វាតាត្រឡប់មកដល់ផ្ទះវិញទាំងទឹកមុខស្រងូតស្រងាត់។ វាតានិយាយទៅកាន់ឪពុកនាងថា៖ «ប៉ា! តើយើងត្រឡប់ទៅរស់នៅផ្ទះចាស់របស់យើងវិញបានទេ? នៅទីនេះ ខ្ញុំគ្មានមិត្តភក្តិទាល់តែសោះ។»

ឪពុករបស់វាតាតបវិញថា៖ «នេះជាផ្ទះយើងហើយណាកូន។ មីងពន្លឺ នឹងមកលេងយើងឆាប់ៗនេះ។»

វាតាស្រាប់តែញញឹមភ្លាមមួយរំពេចព្រោះនាងចូលចិត្តមីងពន្លឺណាស់។ មីងពន្លឺ តែងតែស្តាប់រឿងរ៉ាវ ដែលវាតានិយាយប្រាប់ ហើយគាត់តែងតែនិទានប្រាប់ពីរឿងរ៉ាវរបស់គាត់ជាអ្នកឆុងកាហ្វេផងដែរ។





«សួស្តី! តើមាននរណានៅផ្ទះដែរទេ?» សំឡេងមនុស្សម្នាក់ស្រែកហៅពីខាងក្រៅផ្ទះ។ វាតាស្រែកស្ទើរភ្លាត់សំឡេង «មីងពន្លឺ!»។

បន្ទាប់មក នាងក៏រត់ទៅទទួលគាត់។ មីងពន្លឺ និយាយឡើងថា៖ «សួស្តីក្មួយវាតា។» មីងពន្លឺ ឱបវាតាយ៉ាងណែន រួចហុចទឹកកកឈូសមួយកែវឱ្យនាង។ «មីងទិញទឹកកកឈូសនេះដើម្បីអបអរក្មួយដែលបាន មករស់នៅផ្ទះថ្មីនេះ។»



មីងពន្លឺ និងវាតា ក៏អង្គុយចុះ។
មីងពន្លឺបានសួរសំណួរជាច្រើនអំពីផ្ទះថ្មីរបស់វាតា។
បន្ទាប់មក មីងពន្លឺ
សួរអំពីមិត្តថ្មីរបស់វាតាម្តង។
វាតាតបវិញទាំងមិនសប្បាយចិត្តថា៖ «ខ្ញុំអត់មានមិត្តថ្មីទេ
មីង។»



មីងពន្លឺនិយាយថា៖ «ក្មួយស្រីរបស់មីងប្រាកដជាមិន
សប្បាយចិត្តទេ»។ «ពិតជាគួរឱ្យអាណិតណាស់។» វាតាញ៉ាំទឹក
កកឈូសបណ្ដើរ មើលមុខមីងពន្លឺបណ្ដើរ។
នាងនិយាយទៅកាន់មីងពន្លឺថា៖ «មីងធ្លាប់ប្រាប់ខ្ញុំថា ពីមុនមីង
គឺជាអ្នកឆុងកាហ្វេ។ តើមីងយល់យ៉ាងណា ប្រសិនបើយើងសុំ
ប៉ាបើកតូបលក់ទឹកកកឈូសនៅ មុខផ្ទះ?»
មីងពន្លឺតបវិញទាំងភ្ញាក់ផ្អើល៖ «ពិតមែនហើយក្មួយ! ជាធម្មតា
ក្មេងៗចូលចិត្តញ៉ាំ ទឹកកកឈូសណាស់។ នៅពេលនោះ នឹង
មានមនុស្សជាច្រើនមកទិញទឹកកកឈូសរបស់យើង។»



វាតា តបវិញដោយញញឹមញញែមថា៖ «តើមីងនឹងជួយខ្ញុំលក់ទឹកកកឈូសដែរឬទេ?»

មីងពន្លឺ៖ «មីងប្រាកដជាជួយក្មួយ។ មីងដឹងថា ប៉ាក្មួយមានម៉ាស៊ីនឈូសទឹកកក មួយគ្រឿងដែរ»។

វាតា៖ «យើងត្រូវមានចំណិតត្នោត គ្រាប់ជី និងចាហួយខ្មៅ សម្រាប់ដាក់បន្ថែមជាមួយទឹកកកឈូស!»



វាតា និងមីងពន្លឺរៀបចំតុមួយនៅខាងមុខផ្ទះ។ មីងពន្លឺ បានបញ្ជាទិញទឹកកកពីមិត្តរបស់គាត់ ហើយគាត់ កំពុងពិនិត្យមើលទឹកកកយ៉ាងម៉ត់ចត់។

វាតា សម្លឹងដោយងឿងឆ្ងល់ រួចសួរថា៖ «តើមីងកំពុងមើលអ្វី? វាគ្រាន់តែជាទឹកកកទេតើ?»

មីងពន្លឺញញឹម ហើយនិយាយ៖ «មីងដឹងហើយថាវាគ្រាន់តែជាទឹកកក ប៉ុន្តែគ្រឿងផ្សំដ៏សំខាន់របស់ ទឹកកកឈូស គឺ ទឹកកក។»



មីងពន្លឺ ពន្យល់ប្រាប់វាតាថា៖ «នៅពេលមីងធ្វើការជាអ្នកឆុងកាហ្វេ មីងបានរៀនពិនិត្យគ្រឿងផ្សំយ៉ាង ម៉ត់ចត់។ ប្រសិនបើគ្រាប់កាហ្វេមិនស្រស់ល្អទេ កាហ្វេក៏មិនមានរសជាតិឆ្ងាញ់ដែរ។

មិនតែប៉ុណ្ណោះ អ្នកឆុងកាហ្វេត្រូវយកចិត្តទុកដាក់លើរបៀបកិនគ្រាប់កាហ្វេថែមទៀតផង។ យ៉ាងណាមិញ ការធ្វើទឹកកកឈូសក៏ដូច្នេះដែរ គឺយើងត្រូវពិនិត្យទឹកកក ទឹកស្ករ និងគ្រឿងផ្សំផ្សេងទៀត។»

វាតាបន្ថែមថា៖ «ដូច្នេះ យើងត្រូវការទឹកកកថ្មី ដែលមានគុណភាពល្អ ហើយយើងត្រូវឈូសទឹកកកឱ្យបាន ត្រឹមត្រូវ!»

មីងពន្លឺ និយាយបន្ថែមដែរថា៖ «ហើយយើងត្រូវជ្រើសរើសមើមត្រាវ គ្រាប់ជី និងចាហួយខ្មៅ ដែលមានគុណភាពល្អបំផុត!»



នៅរសៀលថ្ងៃនោះ វាតា និងមីងពន្លឺ លក់ទឹកកកឈូសសម្រាប់អ្នកជិតខាងបណ្ដើរ ហើយជជែកគ្នាបណ្ដើរ។
ប៉ុន្តែវាតា មិនចេះនិយាយរាក់ទាក់ទៅកាន់អ្នកទិញទាំងនោះឡើយ។



បន្ទាប់មក វាតាកត់សម្គាល់ថា មីងពន្លឺ តែងជជែកលេងយ៉ាង
ស្និទ្ធស្នាលជាមួយអ្នកទិញ។
គាត់និយាយយ៉ាងគួរសម ឬសួរសំណួរទៅកាន់អ្នកទិញ។
នៅពេលអ្នកទិញបានឆ្លើយនឹងសំណួររបស់គាត់ហើយ មីងពន្លឺ
ក៏ចាប់ផ្តើមសួរសំណួរមួយទៀត។
បន្ទាប់មក មីងពន្លឺ និងអ្នកទិញ បន្តនិយាយគ្នាពីនេះពីនោះ
ជាហូរហែ។ មីងពន្លឺពិតជាអស្ចារ្យណាស់! វាតា តាំងចិត្តថា នាង
ត្រូវតែសាកល្បងនិយាយ។



ថ្ងៃបន្ទាប់ វាតានិយាយសរសើរមីងអ្នកទិញម្នាក់ថា៖ «ខ្ញុំស្រឡាញ់អាវរបស់មីងណាស់ ព្រោះវាមានម៉ូតស្អាត។» អ្នកទិញនោះញញឹម ហើយនិយាយអរគុណ វាតា។

គាត់បន្តទៀតថា៖ «ក្មួយស្រីរបស់ខ្ញុំជាអ្នកកាត់អាវនេះឱ្យខ្ញុំ។»

«ក្មួយស្រីរបស់មីងពិតជាពូកែមែន។» វាតាសួរបន្ថែមថា៖ «តើក្មួយស្រីមីងបានកាត់អាវផ្សេងទៀតឱ្យមីងដែរឬទេ?»

វាតា និងមីងអ្នកទិញនោះ បន្តជជែកគ្នាអំពីក្មួយស្រីរបស់គាត់ជាហូរហែ ។



ក្រោយពីមីងអ្នកទិញនោះចេញទៅ វាតានិយាយប្រាប់ មីងពន្លឺ ថា៖ «មីង! នៅពេលខ្ញុំនិយាយជាមួយ មីងម្នាក់នោះ ខ្ញុំមាន អារម្មណ៍ភ័យខុសធម្មតា។»

មីងពន្លឺ និយាយលើកទឹកចិត្តដល់វាតាថា៖ «ក្មួយធ្វើបានល្អ ណាស់។ នៅពេលមីងធ្វើជាអ្នក ឆុងកាហ្វេ មីងដឹងថា មនុស្ស ចូលចិត្ត ចែករំលែកពីរឿងរ៉ាវរបស់ខ្លួនទៅវិញទៅមក។ មនុស្សយើងសប្បាយចិត្តនឹងការជជែកគ្នា ប៉ុន្តែលុះត្រាតែមាន មនុស្សម្នាក់ជាអ្នកចាប់ផ្តើម និយាយមុន។ ដូច្នេះ ក្មួយត្រូវតែ ចាប់ផ្តើមនិយាយ ទៅកាន់អ្នកទិញមុន។»

វាតាតបវិញថា៖ «មនុស្សមានច្រើនប្រភេទណាស់ ហើយពួកគេ

មានរឿងរ៉ាវផ្សេងៗគ្នាជាច្រើន!»



នៅល្ងាចថ្ងៃនោះ ប៉ារបស់វាតា បានសួរនាងអំពីរឿងរ៉ាវដែល
កើតឡើងពេញមួយថ្ងៃកន្លងមក។ វាតា
និយាយដោយរីករាយថា៖ «ខ្ញុំសប្បាយចិត្តខ្លាំងណាស់ប៉ា ព្រោះ
ខ្ញុំបានជួបមនុស្សជាច្រើននាក់។»
វាតា និយាយបន្តដោយក្រៀមក្រំថា៖ «ប៉ុន្តែពួកគេនៅមិនបាន
យូរទេ ហើយគ្មានក្មេងណាម្នាក់មកតូបរបស់យើងទេ។»



នៅពេលពួកគេអង្គុយញ៉ាំអាហារពេលល្ងាច វាតាមានគំនិតមួយ។

វាតាសួរថា៖ «តើយើងអាចដាក់កៅអី និងតុបន្ថែមក្នុងតូបរបស់យើង បានទេ? យើងប្រហែលអាច ប្រើប្រាស់ទីធ្លានៅចំហៀងផ្ទះសម្រាប់ឱ្យអ្នកទិញចូលមកអង្គុយ និងជជែកគ្នាបានយូរ។»

មីងពន្លឺនិយាយថា៖ «គំនិតល្អ! ផ្នែកដ៏សំខាន់មួយសម្រាប់អ្នកឆុងកាហ្វេគឺត្រូវជួយបង្កើតជាសហគមន៍មួយ ដោយផ្ដល់ទីកន្លែងងាយស្រួលឱ្យមនុស្សជួបជជែកគ្នា។»



នៅថ្ងៃបន្ទាប់ វាតា និងមីងពន្លឺ នាំគ្នារំកិលតូបទឹកកកឈូសទៅជ្រុងម្ខាងនៃផ្ទះ។
ពួកគេរើប្រអប់ចាស់ៗ ចេញ រួចដាក់កៅអី និងតុមួយចំនួនវិញ។



ប៉ុន្មានថ្ងៃក្រោយមក វាតា និងមីងពន្លឺ ធ្វើទឹកកកឈូសលក់
នៅពេលរសៀល។
មនុស្សកាន់តែច្រើនបានចូលទិញទឹកកកឈូស និងអង្គុយ
ជជែកគ្នាលេងនៅទីនោះ។



នៅថ្ងៃចុងសប្ដាហ៍ វាតាឈរលក់ទឹកកកឈូស ហើយ
បានឃើញក្មេងស្រីបីនាក់ឈរតម្រង់ជួរចាំទិញ ទឹកកកឈូស
នៅតូបរបស់នាង។
ពួកគេទាំងបីនាក់នៅតែពាក់ខ្សែកដ៏ស្រស់ស្អាតដូចៗគ្នា!
បេះដូងរបស់វាតាចាប់ផ្ដើមលោតញាប់ជាថ្មីម្ដងទៀត។



បន្ទាប់ពីស្ដាប់ការបញ្ជាទិញរបស់ក្មេងស្រីទាំងបីហើយ វាតា
និយាយសរសើរថា៖ «ខ្ញុំចូលចិត្តខ្សែករបស់ពួកឯងណាស់។»
ក្មេងស្រីទីមួយតបថា៖ «អរគុណ! យើងទាំងបីនាក់បានធ្វើខ្សែក
នេះជាមួយគ្នា។ ខ្ញុំមិនធ្លាប់ឃើញមានតូបនេះពីមុនមកទេ។ តើ
ប៉ារបស់ឯងទើបនឹងបើកមែនទេ?»
វាតាតបវិញថា៖ «មិនមែនទេ។ គឺខ្ញុំជាអ្នកបើក ហើយមីងពន្លឺជា
អ្នកជួយខ្ញុំ។»



ក្មេងស្រីទាំងនោះភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកគេគិតថា វាតាមាន
តូបលក់ទឹកកកឈូសដោយខ្លួនឯងគឺពិតជា អស្ចារ្យណាស់។
នៅថ្ងៃបន្ទាប់ ក្មេងស្រីទាំងបីនាក់ត្រឡប់មកតូបទឹកកកឈូស
ម្តងទៀត។
ពួកគេហៅវាតាឱ្យអង្គុយលេងជាមួយគ្នា។



ថ្ងៃក្រោយមក ក្មេងស្រីទាំងបីនាក់នោះ បានមកតូបទឹកកក
ឈូសជារៀងរាល់ថ្ងៃ។
មិនយូរប៉ុន្មាន មានក្មេងៗកាន់តែច្រើនមកទិញទឹកកកឈូសនៅ
តូបរបស់វាតា។



មួយរយៈក្រោយមក មីងពន្លឺបានឆៀងចូលមកលេង និង
ដើរតម្រង់ទៅកាន់តូបរបស់វាតា។
មីងពន្លឺ ស្រែកសួរថា៖ «អ្នកលក់! តើខ្ញុំសុំទិញទឹកកកឈូសដ៏
ល្បីល្បាញ មួយកែវផងបានដែរទេ?»
វាតា និយាយដោយញញឹមថា៖ «សូមអញ្ជើញចូល!»



Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ខ្ញុំមានមិត្តហើយ (A Treat for Everyone)*, Author: The Asia Foundation - Let’s Read. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/